**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៦០
ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩
សាលដីកា
លេខ: ០៧ (I)
ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

# សាលដីកា
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោក [redacted] ចៅក្រម

៥.លោកស្រី [redacted] ចៅក្រមរបាយការណ៍

### ក្រឡាបញ្ជីសវនាការ

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ចំពោះ សាលដីកាព្រហ្មទណ្ឌលេខ ៤៥ ក្រIV អប ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន៖

### ជនជាប់ចោទ៖

ឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ គាដ៉ោ សង្កាត់ទិរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted]



Scanned with CamScanner

[redacted] ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ [redacted] មានកូន០១នាក់ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ)។

(ឃុំខ្លួននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៧) នៅពន្ធនាគារខេត្តកំពង់ចាម។

អ្នកតំណាងដោយអាណត្តិ៖ លោកមេធាវី [redacted] ប៊ុណ្ណារិទ្ធ ។

**ជាប់ចោទពីបទៈ** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចអូរតាសែង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អំពីអង្គហេតុ**

កាលពីថ្ងៃ០៩ ខែកញ្ញា ឆ្នាំ២០១៧ កម្លាំងជំនាញបានទទួលព័ត៌មានពីភ្នាក់ងារឈ្មោះ [redacted] ធារ៉ា ភេទប្រុស អាយុ២២ឆ្នាំ ថាមានការលក់ចែកចាយគ្រឿងញៀននៅស្រុកចំការលើ ក្រោយពីទទួលបានព័ត៌មានភ្លាម កម្លាំងជំនាញក៏បានប្រើប្រាស់វិធានញុះញង់ ដោយឲ្យមានការលក់ទិញថ្នាំញៀនខុសច្បាប់ និងមានឃ្លាំមើល ដោយប្រគល់ប្រាក់រៀលចំនួន ៤០.០០០រៀល ឲ្យទៅភ្នាក់ងារ មានប្រភេទក្រដាស់ប្រាក់មួយម៉ឺនរៀលចំនួន ០៤សន្លឹក មានលេខ គ៣.៨៤៨៤៣០៦ ជ៥.៩៨៦៦៨ ៨២, កឲ.៣៨៨៣៥៣៨, គ៥.១០២០២៧៧ ដើម្បីទៅទិញថ្នាំញៀនពីឈ្មោះ [redacted] ធារ៉ា ភេទស្រី អាយុ១៦ឆ្នាំ ដោយបានទូរស័ព្ទទាក់ទងទិញថ្នាំញៀន និងណាត់ជួបនៅចំនុចភូមិអូរតាសែង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម ។ លុះដល់វេលាម៉ោង ១៣ម៉៥០នាទី កម្លាំងជំនាញក៏បានធ្វើការបង្ក្រាបករណី ជួញដូរថ្នាំញៀន និងបានឃាត់ខ្លួនជនសង្ស័យបានចំនួន ០៣នាក់ ១.ឈ្មោះ [redacted] ធារ៉ា ភេទស្រី អាយុ១៦ឆ្នាំ ២.ឈ្មោះ [redacted] ធា ភេទប្រុស អាយុ២២ឆ្នាំ និង៣.ឈ្មោះ [redacted] សុខហៀង ភេទប្រុស អាយុ២៦ឆ្នាំ និងដកហូតបានថ្នាំញៀនចំនួន ៣១កញ្ចប់ (ធំចំនួន ០១កញ្ចប់) ទូរស័ព្ទដៃចំនួន ០២គ្រឿង រួចកម្លាំងជំនាញក៏បាននាំជនសង្ស័យទាំងបីនាក់មកអធិការដ្ឋាននគរបាលស្រុកចំការលើ ដើម្បីធ្វើការសាកសួរ។ ក្រោយពេលសាកសួរជនសង្ស័យឈ្មោះ [redacted] ធារ៉ា សារភាពថាថ្នាំញៀន ដែលសមត្ថកិច្ចរកឃើញគឺពិតជារបស់ខ្លួនមែន ថ្នាំញៀននោះគឺខ្លួននិងប្តីរបស់ខ្លួនឈ្មោះ [redacted] នី ហៅ ទក ទិញពីបងថ្លៃឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ភេទប្រុស នៅភូមិជាមួយគ្នាដើម្បីយក ទៅលក់បន្ត ចំណែកជនសង្ស័យឈ្មោះ [redacted] ធា ភេទប្រុស និងឈ្មោះ [redacted] ហៀង ទាំងពីរនាក់បានសារភាពថាពួកគេមិនដែល ជួញដូរថ្នាំញៀនទេ គឺពួកគេចេះតែប្រើប្រាស់ប៉ុណ្ណោះ ហើយថ្នាំញៀនដែរប្រើកន្លងមក គឺទិញពីឈ្មោះ [redacted] នី ហៅ ទក បន្ទាប់ពីធ្វើការសាកសួររួចមកតំណាងអយ្យការបានបញ្ជូនជន សង្ស័យឈ្មោះ [redacted] ធា ភេទប្រុស និងឈ្មោះ [redacted] ហៀង ភេទប្រុស ទៅមន្ទីរពេទ្យបង្អែកចំការលើ ដើម្បីបន្សាបគ្រឿងញៀន ។

-បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ០៩(ក) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

Scanned with CamScanner

១.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ផារ៉ាំ ភេទស្រី អាយុ១៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០១ ឆ្នាំ (មួយឆ្នាំ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូរតាសែង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.ផ្តន្ទាទោសលើជនជាប់ចោទ:

ក.ជនជាប់ចោទឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ភេទប្រុស អាយុ២២ឆ្នាំ ជាតិខ្មែរ

ខ.ឈ្មោះ [redacted] នី ហៅ ទក ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៣ឆ្នាំ (បីឆ្នាំ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិអូរតាសែង ឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៧ តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.បង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] នី ហៅ ទក តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤.វត្ថុតាងរួមមាន

ក.ថ្នាំញៀនប្រភេទមេតំហ្វេតាមីន ចំនួន៣១កញ្ចប់ មានទម្ងន់ ១២.៤៥ក្រាម ,ទូរស័ព្ទដៃចំនួន០២គ្រឿង និងកាំភ្លើងកែឆ្នៃ០១គ្រឿង និងដាវ០១ ដើម ត្រូវរឹបអូសបំផ្លាញចោល។

ខ.ម៉ូតូចំនួន០៤គ្រឿងចាស់ ម៉ាក MSX ចំនួន០១គ្រឿង ម៉ាកហុងដាឌុប៥០ ពណ៌ខៀវ ចំនួន០១គ្រឿង ម៉ាកសេ ១០០ កូរ៉េពណ៌ក្រហមចំនួន ០១គ្រឿង និងម៉ាកវេវឆ្លឹងពណ៌ខៀវ ចំនួន ០១គ្រឿង ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

៥.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផារ៉ាំ និងឈ្មោះ [redacted] ទិត្យា ហៅ យ៉ា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] នី ហៅ ទក បើភាគីណាមិនសុខចិត្ត និងសេចក្តីសម្រេចនេះ មានសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ១៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ដោយហេតុថា ការសម្រេចសេចក្តី គឺពុំមានភាពយុត្តិធម៌ចំពោះរូបខ្ញុំបាទឡើយ។

-បានឃើញ អំណាចសាលដីការដ្ឋប្បវេណីលេខ ៤៥ក្រIV(អប) ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់ជនជាប់ចោទ ឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ទុកជាត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។



Scanned with CamScanner

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩(គ) ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការដដែល។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធឲ្យជនជាប់ចោទនិងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩។

ទុកសិទ្ធិឲ្យប្តឹងសាទុក្ខនៅក្នុងកំណត់ច្បាប់ ។

-បានឃើញ សារណាការពាររបស់លោក [redacted] ប៊ុណ្ណារិទ្ធ មេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានសុំថា៖

សាលាដំបូង និងសាលាឧទ្ធរណ៍បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] ទិត្យា ហៅ យ៉ា ដាក់ពន្ធនាគារកំណត់ ០៣ (បី)ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួត ពិនិត្យគ្រឿងញៀន គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។ ដោយផ្អែកតាមសំអាងហេតុរបស់សាលាដំបូង និងសាលាឧទ្ធរណ៍ គឺមានភស្តុតាងសុីសង្វាក់ទៅនឹងចម្លើយជនជាប់ចោទ ផ្សេងទៀតព្រមទាំងផ្អែក តាមកំណត់ហេតុដែកឆេររបស់មន្ត្រីនគរបាលយុត្តិធម៌ ដកហូតវត្ថុតាងជាក់ស្តែងពីបក្សពួកឈ្មោះ [redacted] ដារ៉ា និង ឈ្មោះ [redacted]នី ហៅ ទក ថ្នាំញៀនចំនួន ១៨កញ្ចប់ និង ០១កញ្ចប់ធំ នៅផ្ទះ និង៣១ កញ្ចប់តូច ឯកសារលេខ ០៤ លេខ ២៨ និងលេខ ៣៧ ។ ដូចគ្នាតាមសំអាងហេតុរបស់សាលាឧទ្ធរណ៍បានបញ្ជាក់ត្រឹមត្រូវដូចនៅក្នុងចំណុច ៣,៤,៦,៧ និងចំនុច ៨ ស្រាប់។

## តំណាងមហាអយ្យការ ស្នើក្រុមប្រឹក្សាជំនុំជំរះសម្រេច

១-ទទួលបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted]ទិត្យា ហៅ យ៉ា ទុកជាត្រឹមត្រូវតាមទម្រង់ តែផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៥ក្រIV(អប) ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

+ជនជាប់ចោទឈ្មោះ [redacted]ទិត្យា ឆ្លើយថា ខ្ញុំបាទមាន អាយុ២២ឆ្នាំ ប្រពន្ធឈ្មោះ [redacted]មានកូន ២នាក់ សព្វថ្ងៃ ឃុំខ្លួននៅពន្ធនាគារខេត្តកំពង់ចាម។



Scanned with CamScanner

ខ្ញុំបាទទុកសិទ្ធិអោយមេធាវីខ្ញុំសន្និដ្ឋាន ។

+លោកមេធាវី [redacted] ប៊ុណ្ណារិទ្ធ ការពារជនជាប់ចោទឈ្មោះ [redacted] ទិត្យា ធ្វើសេចក្តីសន្និដ្ឋានថា ក្នុងរឿងនេះ កូនក្តីខ្ញុំ មិនបានជួញដូរគ្រឿងញៀនទេ ដាក់ទោសកាត់៣ឆ្នាំ មិនត្រឹមត្រូវទាល់តែសោះ សុំក្រុមប្រឹក្សាមេត្តាពិចារណា ទៅលើអង្គហេតុ និងអង្គច្បាប់បើគាត់ពាក់ព័ន្ធមែន ត្រូវមានភស្តុតាង តែនេះគ្មានទេ។

សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ និងសុំលើកលែងការចោទប្រកាន់លើកូនក្តីខ្ញុំបាទ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនិងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ទិត្យា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមបទបញ្ញត្តិមាត្រា៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា សេចក្តីសន្និដ្ឋានការពារក្តីរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទបានលើកឡើងអះអាងនាពេលសវនាការចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ក៏ដូចជាសារណាលាយលក្ខណ៍អក្សរដែរ ដោយគ្រាន់តែលើកឡើងអធិប្បាយអំពីអង្គហេតុសារឡើងវិញ រួចអះអាងថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] សត្យា ហៅ យ៉ា មិនបានប្រព្រឹត្តអំពើលក់ចែកចាយគ្រឿងញៀន ដូចការចោទប្រកាន់នោះទេ ឯសេចក្តីសម្រេចរបស់របស់តុលាការអង្គសេចក្តីដែលបានសម្រេចមកនេះ ដោយផ្អែកតែទៅលើចម្លើយសារភាពរបស់ជនឈ្មោះ [redacted] ដារ៉ា ភេទស្រី អាយុ ១៦ឆ្នាំ បានឆ្លើយប៉ុណ្ណោះ ដោយមិនបានចាប់ឃាត់ខ្លួនកូនក្តីរបស់ខ្លួនក្នុងករណីជាបទល្មើសជាក់ស្តែងឡើយ ហើយក៏មិនបានចាប់យកវត្ថុតាងជាគ្រឿងញៀនពីកូនក្តីរបស់ខ្លួនដោយផ្ទាល់ដែរ និងស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចឱ្យកូនក្តីរបស់ខ្លួនបានរួចផុតពីបទចោទប្រកាន់ ដោយផ្អែមតាមបទប្បញ្ញត្តិមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ កថាខណ្ឌ១ បានចែងថា *"វិមតិសង្ស័យត្រូវបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច"* នោះ គឺជាសេចក្តីសន្និដ្ឋានមិនមានមូលដ្ឋាន ភស្តុតាងដោះបន្ទុកដែលតុលាការអង្គសេចក្តីបានរកឃើញនោះឡើយ ដោយហេតុថា សក្ខីកម្មរបស់សាក្សី ឬ សក្ខីកម្មជនជាប់ចោទ ឱ្យតែវាមានស៊ីចង្វាក់គ្នានោះគឺជាភស្តុតាងមួយ ក្នុងចំណោមប្រភេទភស្តុតាងផ្សេងទៀត ហើយនៅក្នុងនីតិវិធីត្រួតពិនិត្យបទល្មើស

Scanned with CamScanner

ពាក់ព័ន្ធនឹងសារធាតុញៀន ក៏ដូចជាក្នុងនីតិវិធីត្រួតពិនិត្យបទល្មើសជាទូទៅដែរ វាមិនចាំបាច់តែជាបទល្មើសជាក់ស្តែងទើបអាចធ្វើទៅបាននោះទេ ។

៣-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted]ទិត្យា ហៅ យ៉ា ប្តឹងសាទុក្ខនឹងសាលដីកាព្រហ្មទណ្ឌលេខ ៤៥ ក្រIV "អប" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ មិនមានមូលហេតុនៃបណ្តឹងសាទុក្ខដូចមានបញ្ញត្តក្នុងមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ ។

៤-យល់ឃើញថា តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ ក៏ដូចជាសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរដែរថា ការដែលតុលាការសាលាដំបូងខេត្តកំពង់ចាម និងសាលាឧទ្ធរណ៍បានសម្រេចផ្តន្ទាទោសលើឈ្មោះ [redacted]ទិត្យា ហៅ យ៉ា កំណត់ដាក់ពន្ធនាគាររយៈពេល ៣ ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបទប្បញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀននោះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដោយផ្អែកតាមសំអាងហេតុរបស់តុលាការសាលាដំបូង ក៏ដូចសាលាឧទ្ធរណ៍ដែរ គឺភស្តុតាងស៊ីចង្វាក់គ្នារវាងចម្លើយជនជាប់ចោទផ្សេងទៀត ព្រមទាំងកំណត់ហេតុនៃការរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលបានដកហូតនូវ វត្ថុតាងជាវត្ថុផ្ទុកសារធាតុញៀនពីឈ្មោះ [redacted]ធារ៉ា និងឈ្មោះ [redacted]នី ហៅ ទក នូវថ្នាំញៀនចំនួន ១៨កញ្ចប់ និងមួយកញ្ចប់ធំនៅនឹងផ្ទះ ដូចមានលើកឡើងបញ្ជាក់នៅក្នុងផ្នែកសំអាងហេតុក្នុងសាលដីការបស់សាលាឧទ្ធរណ៍ដែលពាក់ព័ន្ធ ត្រង់ចំណុចទី៣ , ៤, ៦, ៧ និងចំណុចទី៨ និងប្តឹងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់នូវសាលដីកាព្រហ្មទណ្ឌលេខ ៤៥ក្រIV "អប" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល គឺជាសេចក្តីសន្និដ្ឋានមានមូលដ្ឋានសំអាងហេតុត្រឹមត្រូវ សមស្របតាមបញ្ញត្តច្បាប់ ។

៥-យល់ឃើញថាសាលដីកាព្រហ្មទណ្ឌលេខ ៤៥ ក្រIV "អប" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ហើយ ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៧៨ ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted]ទិត្យា ហៅ យ៉ា ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៤៥ ក្រIV "អប" ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

Scanned with CamScanner

[illegible] រាជធានីភ្នំពេញ ទី១០ ខែមករា ឆ្នាំ២០២០ និងប្រកាស[illegible]

[illegible] រាជធានីភ្នំពេញ ទី[illegible] ខែមករា ឆ្នាំ២០២០ ។